## ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

# កិច្ចព្រមព្រៀង
# រវាង
# តំណាងកម្មករនិយោជិត និងសហជីពនៃសណ្ឋាគាររ៉ាហ្វលឡឺរ៉ូយ៉ាល់
# និង
# ក្រុមហ៊ុនសណ្ឋាគាររ៉ាហ្វិលរ៉ូយ៉ាល់

កិច្ចព្រមព្រៀងនេះត្រូវបានធ្វើឡើងនៅថ្ងៃ ទី២២ ខែមិថុនា ឆ្នាំ២០២០ រវាងសហជីពនិយោជិតទេសចរណ៍អាស៊ាននៃសណ្ឋាគាររ៉ាហ្វលឡឺរ៉ូយ៉ាល់(ពីនេះតទៅហៅថា"សហជីព") និង ក្រុមហ៊ុនសណ្ឋាគាររ៉ាហ្វិល រ៉ូយ៉ាល់ (ពីនេះតទៅហៅថា "និយោជក")។ ភាគីនីមួយៗអាចហៅដោយឡែកថា "ភាគី" និងហៅជារួមថា "គូភាគី"។

សណ្ឋាគារ Raffles Hotel Le Royal កំពុងប្រឈមនឹងការលំបាកផ្នែកសេដ្ឋកិច្ចក្នុងកំឡុងពេលនៃជំងឺរាតត្បាតជាសកល COVID-19 ដែលមិនធ្លាប់មានពីមុនមក។ ការផ្ទុះឡើងនៃកូរ៉ូណាវីរុស ទូទាំងពិភពលោកបាននាំមកនូវ ការបញ្ឈប់ការធ្វើដំណើរអន្តរជាតិទាំងអស់ ហេតុដូចនេះហើយ សណ្ឋាគារកំពុងតែជួបប្រទះនូវកម្រិតអាជីវកម្មដែលមិនស្ថិតស្ថេរ។ ដូច្នេះ និយោជក និងសហជីពបានធ្វើការចរចា និងព្រមព្រៀងលើការព្យួរកិច្ចសន្យាការងារកម្មករនិយោជិតចំនួន ១៥៨នាក់ (ស្រី ៦៦នាក់) ក្នុងចំណោមកម្មករនិយោជិតសរុបចំនួន ២៨១នាក់ (ស្រី ៨៧នាក់) រយៈពេល ១៥ថ្ងៃ ដោយគិតចាប់ពីថ្ងៃទី១ ខែកក្កដា ឆ្នាំ២០២០ រហូតដល់ថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០២០។

ក្នុងរយៈពេលនៃការព្យួរកិច្ចសន្យាការងារ គូភាគីបានព្រមព្រៀងគ្នាទទួលយកលក្ខខណ្ឌដូចខាងក្រោម៖

- និយោជិតដែលត្រូវព្យួរកិច្ចសន្យាការងារបណ្ដោះអាសន្ននឹងទទួលបានប្រាក់ឈ្នួល ៥0% នៃប្រាក់ខែគោលរបស់ពួកគេ។
- និយោជិតនឹងមិនទទួលបានប្រាក់ធានានុគ្រោះក្នុងពេលព្យួរកិច្ចសន្យាការងារបណ្ដោះអាសន្ន។
- ការព្យួរកិច្ចសន្យាការងារបណ្ដោះអាសន្ននឹងត្រូវបានផ្ដល់អាទិភាពដោយផ្អែកលើអតីតភាពការងាររបស់និយោជិត តាមផ្នែកនីមួយៗ។
- រាល់អត្ថប្រយោជន៍ដែលមានស្រាប់នឹងបន្តធម្មតា
- អតីតភាពការងារនឹងមិនត្រូវបានប៉ះពាល់

Raffles Royal Hotel Pte., Ltd.

គូភាគីព្រមព្រៀងដោយផ្តិតមេដៃខាងក្រោមនេះ៖

ភាគី តំណាងកម្មករនិយោជិត និងសហជីព

ប៉ាល់ ពិសិដ្ឋ
ប្រធាន

ប៊ុន យឿន
អនុប្រធាន

សូ សារ៉ុន
លេខាធិការ

ភាគីនិយោជក

រាជធានីភ្នំពេញ ថ្ងៃទី២៣ ខែ ០៦ ឆ្នាំ២០២០
ហត្ថលេខា និងត្រា
នាយកសណ្ឋាគារ

Raffles Royal Hotel Pte. Ltd.

Oliver Dudler